# របៀបដែលពួកគេផ្សាយប្រាប់ដំណឹងល្អនេះ



កោះហាវ៉ៃ



ប្រទេសវេនីហ្សូអេឡា



ប្រទេសយូកូស្លាវ៉ា

**ពួកគ្រីស្ទាន**បានត្រូវបញ្ជាថា: «ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍» ។ ប៉ុន្តែរឿងនេះមិនមានន័យថា ពួកគេនឹងត្រូវបង្ខំ ឬក៏ធ្វើឱ្យអ្នកដទៃផ្លាស់ប្ដូរដោយប្រើកម្លាំងនោះឡើយ ។ មុខងារដែលបានប្រគល់ទៅព្រះយេស៊ូគឺ «ឱ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ» «ប្រកាសប្រាប់ពីសេចក្ដីប្រោសលោះដល់ពួកឈ្លើយ» ហើយ «នឹងប្រោសមនុស្សដែលមានចិត្តសង្រេង» ។ (ម៉ាថាយ ២៨:១៩; អេសាយ ៦១:១, ២; លូកា ៤:១៨, ១៩) ស្មរបន្ទាល់ព្រះយេហូវ៉ាខំប្រឹងធ្វើមុខងារនេះដោយប្រកាសដំណឹងល្អពីព្រះគម្ពីរ ។ ដូចជាព្យាការីអេសេគាលពីបុរាណនោះ សព្វថ្ងៃនេះស្មរបន្ទាល់ព្រះយេហូវ៉ាខំប្រឹងស្វែងរក «ពួកមនុស្សដែលដកដង្ហើមធំហើយថ្ងូរ ដោយព្រោះការស្អប់ខ្ពើមដែលមនុស្សប្រព្រឹត្ត» ។ -អេសេគាល ៩:៤

វិធីល្បីល្បាញដែលគេប្រើដើម្បីស្វែងរកមនុស្សដែលមានចិត្តព្រួយដោយព្រោះតែស្ថានភាពសព្វថ្ងៃនេះ គឺ វិធីដើរផ្សាយពីផ្ទះមួយទៅផ្ទះមួយ ។ ពួកគេខំប្រឹងអស់ពីសមត្ថភាពឱ្យជួបសាធារណជន ដូចជាព្រះយេស៊ូបានធ្វើកាលដែល «ទ្រង់យាងទៅប្រដៅក្នុងគ្រប់ក្រុងគ្រប់ភូមិ . . . ព្រមទាំងប្រាប់ដំណឹងល្អពីនគរព្រះ» ។ សិស្សពីដើមរបស់ទ្រង់បានធ្វើយ៉ាងដូច្នោះដែរ ។ (លូកា ៨:១; ៩:១-៦; ១០:១-៩) សព្វថ្ងៃនេះ នៅគ្រប់កន្លែងណាដែលអាចធ្វើបានស្មរបន្ទាល់ព្រះយេហូវ៉ាខំប្រឹងទៅដល់ផ្ទះទាំងអស់ច្រើនដងរៀងរាល់ឆ្នាំ ដើម្បីនិយាយជាមួយនឹងម្ចាស់ផ្ទះពីរបីនាទី អំពីកម្មវត្ថុមួយតាមតំបន់ឬក៏តាមពិភពលោក ដែលជាកង្វល់ឬក៏គេមានការចាប់អារម្មណ៏នោះ ។ គេអាចពិចារណាពីរបីបទគម្ពីរ ហើយបើសិនជាម្ចាស់ផ្ទះយកចិត្តទុកដាក់ ស្មរបន្ទាល់នោះអាចរៀបចំត្រឡប់មកវិញតាមពេលសមគួរ ដើម្បីនិយាយជាមួយគ្នាថែមទៅទៀត ។ អ្នកស្ដាប់អាចទទួលបាននូវព្រះគម្ពីរហើយប្រកាសនវត្ថុដែលជួយពន្យល់ព្រះគម្ពីរ ហើយបើអ្នកម្ចាស់ផ្ទះចង់ គេអាចមានការសិក្សាព្រះគម្ពីរនៅផ្ទះគេដោយឥតគិតថ្លៃ ។ ស្មរបន្ទាល់ព្រះយេហូវ៉ាបានដឹកនាំរាប់លានការសិក្សាព្រះគម្ពីរជាទៀងទាត់

ជាមួយបុគ្គលនិងក្រុមគ្រួសារទូទាំងពិភពលោក ។

វិធីមួយទៀតដែល «ដំណឹងល្អ» នៃព្រះរាជាណាចក្របានត្រូវប្រកាសប្រាប់ដល់អ្នកដទៃ
គឺតាមវិធីកិច្ចប្រជុំដែលមានក្នុងសាលព្រះរាជាណាចក្រនៅកន្លែងនានា ។
ពួកស្មរបន្ទាល់មានកិច្ចប្រជុំនៅទីនោះជារៀងរាល់សប្ដាហ៍ ។
កិច្ចប្រជុំមួយជាសុន្ទរកថាសាធារណៈអំពីប្រធានណាមួយដែលចាប់អារម្មណ៍នៅពេលថ្មីៗ
ហើយបន្តបន្ទាប់នោះមានការសិក្សាប្រធានឬក៏ទំនាយណាមួយខាងព្រះគម្ពីរ ដោយប្រើ*ទស្សនាវដ្ដីប៉មយាម*
ជាប្រភពនៃរឿងនោះ ។
កិច្ចប្រជុំមួយទៀតគឺជាសាលាសម្រាប់អប់រំស្មរបន្ទាល់ម្នាក់ៗឱ្យធ្វើជាអ្នកប្រកាសដំណឹងឱ្យបានប្រសើរ ហើយបន្តគ្នានោះ
មានការពិគ្រោះអំពីកិច្ចបន្ទាល់នៅក្នុងកន្លែងផ្សព្វផ្សាយតាមតំបន់ ។ ថែមទៀតនោះ
មួយសប្ដាហ៍ម្ដងស្មរបន្ទាល់រួមប្រជុំគ្នាក្នុងផ្ទះឯកជន ជាក្រុមតូចៗ ដើម្បីសិក្សាព្រះគម្ពីរដែរ ។





សាធារណជនអាចចូលរួមនឹងកិច្ចប្រជុំទាំងនេះ ។
នៅឯកិច្ចប្រជុំទាំងនេះមិនដែលមានការរៃលុយឡើយ ។
កិច្ចប្រជុំយ៉ាងនេះមានប្រយោជន៍សម្រាប់មនុស្សគ្រប់ៗគ្នា ។
ព្រះគម្ពីរបានថែងថា:
«ត្រូវឱ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ
ដើម្បីនឹងបណ្ដាលឱ្យមានសេចក្ដីស្រឡាញ់ ហើយឱ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ។
ត្រូវឱ្យកំឡាចិត្តគ្នាវិញ ឱ្យកាន់តែខ្លាំងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ» ។
ការសិក្សានិងការស្រាវជ្រាវដោយខ្លួនឯងនោះជាការចាំបាច់
ប៉ុន្តែរួមប្រជុំជាមួយអ្នកដទៃជួយឱ្យចម្រើនដូចដែលបានថែងថា: «ដែករមែងសំលៀងដែក ឯមនុស្ស
ក៏ធ្វើឱ្យមិត្រសំឡាញ់ខ្លួនមុតស្រួចយ៉ាងនោះដែរ» ។–ហេព្រើរ ១០:២៤, ២៥; សុភាសិត ២៧:១៧

**សាលព្រះរាជាណាចក្រជាកន្លែងដែល
បានគូរប្លង់មក ឱ្យមានប្រយោជន៍
សម្រាប់ការពិគ្រោះព្រះគម្ពីរ**

ស្មរបន្ទាល់ព្រះយេហូវ៉ាឆ្លៀតយកប្រយោជន៍ពីឱកាសជាច្រើន
ដើម្បីនិយាយអំពីដំណឹងល្អកាលគេជួបមនុស្សឯទៀតតាមជីវភាពធម្មតារបស់គេនោះ ។
គេប្រហែលជានិយាយបន្តិចបន្តួចជាមួយនឹងអ្នកជិតខាងម្នាក់ ឬក៏ជាមួយនឹងអ្នកធ្វើដំណើរជាមួយគ្នានៅរថយន្តធំ
ឬនៅយន្តហោះ ឬការសន្ទនាយូរបន្តិចជាមួយនឹងមិត្តសំឡាញ់ ឬជាមួយនឹងបងប្អូនម្នាក់
ឬមានការសន្ទនាជាមួយនឹងអ្នកដែលធ្វើការជាមួយនៅពេលសម្រាកបរិភោគអាហារ ។
កិច្ចបន្ទាល់ជាច្រើនដែលព្រះយេស៊ូបានធ្វើគឺតាមរបៀបទាំងនេះ–

កាលដែលទ្រង់ដើរតាមមាត់សមុទ្រគង់នៅលើចង្កេះភ្នំតូចៗ ពេលដែលទទួលទាននៅផ្ទះរបស់គេ
ទៅរួមមង្គលការរបស់គេ ឬក៏បានធ្វើដំណើរដោយទូកនៅសាទត្រីនៅសមុទ្រកាលីឡេផង ។
ទ្រង់បានបង្រៀនតាមសាលាប្រជុំហើយក្នុងព្រះវិហារនៅក្រុងយេរូសាឡិម ។ នៅទីណាក៏ដោយដែលទ្រង់គង់នៅ
ទ្រង់បានស្វែងរកឱកាសដើម្បីឱ្យមានព្រះបន្ទូលអំពីព្រះរាជាណាចក្រ ។
ស្មរបន្ទាល់ព្រះយេហូវ៉ាខំប្រឹងយកតម្រាប់តាមរបៀបនេះដែរ ។–ពេត្រុសទី១ ២:២១

## ផ្សាយប្រកាសដោយគំរូ



ក្នុងជីវភាពគ្រួសាររបស់គេ ក៏ដូចជាកាលដែលគេជួបមនុស្សដទៃដែរ ពួកស្មរបន្ទាល់ខ្ទះខ្នែងដោយចិត្តស្មោះដើម្បីអនុវត្តតាមអ្វីដែលគេអនុសាស
ដល់អ្នកដទៃ

វិធីប្រកាសប្រាប់ដំណឹងល្អទាំងអស់នេះនឹងមិនមានខ្លឹមសារចំពោះលោកអ្នកទេ
បើសិនជាមនុស្សដែលធ្វើសេចក្ដីប្រកាសនេះ
មិនបានអនុវត្តតាមការបង្រៀនទាំងនោះខ្លួនឯងជាមុនសិន ។
បើនិយាយយ៉ាងនេះរួចទៅធ្វើយ៉ាងនោះវិញឈ្មោះថាជាការលាក់ពុត
ហើយការលាក់ពុតខាងសាសនាបានធ្វើឱ្យមនុស្សរាប់លាននាក់បែរ ចេញពីព្រះគម្ពីរ ។
ការបន្ទោសទៅលើព្រះគម្ពីរក្នុងរឿងនេះជាការមិនត្រឹមត្រូវទេ ។
ពួកអាចារ្យនិងពួកផារិស៊ីធ្លាប់មានបទគម្ពីរហេព្រើរនោះ ។
ប៉ុន្តែព្រះយេស៊ូបានកាត់ទោសពួកគេថាជាអ្នកមានពុតទៅវិញ ។ ទ្រង់មានបន្ទូលអំពីការអានរបស់គេពីក្រិត្យវិន័យរបស់លោកម៉ូសេ រួចមានបន្ទូលដល់ពួកសិស្សរបស់ទ្រង់ទៀតថា:
«ដូច្នេះគ្រប់ទាំងសេចក្ដីណាដែលគេប្រាប់ឱ្យអ្នករាល់គ្នាកាន់តាម នោះចូរកាន់ហើយប្រព្រឹត្តតាមចុះ ។
ប៉ុន្តែកុំឱ្យប្រព្រឹត្តតាមអំពើរបស់គេឡើយ ដ្បិតគេគ្រាន់តែ ថា តែមិនធ្វើតាមទេ» ។ (ម៉ាថាយ ២៣:៣)
គំរូខាងជីវភាពដ៏ត្រឹមត្រូវរបស់ពួកគ្រីស្ទាន អាចប្រកាសបានប្រសើរជាងការទេសនារាប់ម៉ោងទៅទៀត ។
សេចក្ដីនេះបានត្រូវថែងប្រាប់ដល់ភរិយាជាគ្រីស្ទាន ដែលមានស្វាមីមិនមែនជាអ្នកជឿថា:
«នោះប្រពន្ធនឹងទាញចិត្តមកបានដោយសារកិរិយាល្អក្រៅពីព្រះបន្ទូល ដោយអ្នកនោះឃើញកិរិយាបរិសុទ្ធ
ដែលប្រពន្ធប្រព្រឹត្តយ៉ាងកោតខ្លាចដល់ព្រះ» ។–ពេត្រុសទី១ ៣:១, ២

ហេតុដូច្នេះហើយ ស្មរបន្ទាល់ព្រះយេហូវ៉ាខ្នះខ្នែងណែនាំឱ្យមនុស្សស្គាល់ដំណឹងល្អនេះតាមរបៀបនេះដែរ:
ដោយធ្វើជាគំរូដ៏ល្អក្នុងមារយាទគ្រីស្ទានដែលគេអនុសាសទៅអ្នកដទៃទៀតនោះ ។ ពួកគេខ្នះខ្នែងធ្វើតាមពាក្យសំដីនេះ:
«អស់ទាំងការអ្វី ដែលអ្នកចង់ឱ្យមនុស្សលោក ប្រព្រឹត្តនឹងខ្លួន នោះត្រូវឱ្យអ្នកប្រព្រឹត្តនឹងគេដែរ» ។ (ម៉ាថា ៧:១២)
គេខ្នះខ្នែងប្រព្រឹត្តបែបនេះនឹងមនុស្សទាំងអស់គ្នា គឺមិនគ្រាន់តែជាមួយនឹងស្មរបន្ទាល់គ្នាឯង ពួកសំឡាញ់ ពួកអ្នកជិតខាង
ឬក៏នឹងបងប្អូនប៉ុណ្ណោះទេ ។ ដោយពួកគេមិនមានភាពល្អឥតខ្ចោះនោះ



ពួកគេមិនបានជោគជ័យ១០០ភាគរយជានិច្ចនោះឡើយ ។
ប៉ុន្តែជាសេចក្ដីប៉ងប្រាថ្នាពីចិត្តរបស់គេ ឱ្យធ្វើការល្អដល់មនុស្សគ្រប់ៗគ្នា
មិនគ្រាន់តែដោយការផ្សាយប្រកាសដំណឹងល្អនៃព្រះរាជាណាចក្រប៉ុណ្ណោះទេ
គឺថែមទាំងជួយអ្នកដទៃតាមរបៀបផ្សេងៗ កាលណាដែលអាចធ្វើទៅបានផង ។ — យ៉ាកុប
២:១៤-១៧

Copyright © 2004 Watchtower Bible and Tract Society of Pennsylvania. All rights reserved.